ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ២៥១

ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

សាលដីកា

លេខ : ១០៩

ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៤

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឌិត** | **មុន្ធី** | ជាប្រធាន |
| ២-លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៣-លោក | ជីវ | កេង | ជាចៅក្រម |
| ៤-លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៥-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៦-លោក | យស់ | សួខឿន | ជាចៅក្រម |
| ៧-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រមរបាយការណ៍ |
| ៨-លោក | ម៉ុង | មុនីចរិយា | ជាចៅក្រម |
| ៩-លោក | យូរ | ឧត្តរា | ជាចៅក្រម |

ក្រឡាបញ្ជី

លោក **ស៊ិន នារ:**

តំណាងមហាអយ្យការ

លោក **ឈុន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ ៣៥"យ" ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ទៀង ចាន់ធីញ** ( ជាម្ចាស់បណ្តឹងសាទុក្ខ ) អាយុ៣១ឆ្នាំ ជាតិចិន មុខរបរ ពាណិជ្ជករ ទីលំនៅផ្ទះលេខ ៣៣, ៣៥ ផ្លូវ១២២ សង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

លោក ខៀវ សិទ្ធផន ជាមេធាវីការពារ និង តំណាង ។

និង លោក លឹម វណ្ណា ជាមេធាវីការពារ ។

តតិយជនឈ្មោះ **លឹង ស៊ុញហ្វ** អាយុ ៣៧ឆ្នាំ ផ្ទះលេខ ៧៧ ផ្លូវមុនីរ៉េត សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

លោក ជីវ សាន ជាមេធាវីការពារ និង ជាតំណាង ។

ចុងចម្លើយឈ្មោះ**ខុង ឆាលី** (ជាម្ចាស់បណ្ដឹងសាទុក្ខ) អាយុ៥៧ឆ្នាំ មុខរបរពាណិជ្ជករ ទីលំនៅផ្ទះលេខ ៣៣,៣៥ ផ្លូវ១២២ សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។

លោក សៅ វីតា ជាមេធាវីការពារ និង ជាតំណាង ។

តតិយជនឈ្មោះ**ខូវ ប៉ោសៀង** (ជាម្ចាស់បណ្ដឹងសាទុក្ខ) អាយុ៣៧ឆ្នាំ ទីលំនៅនៅក្រុមទី១៦ សង្កាត់លេខ២ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

លោក ហេង សុធាវណ្ណារិទ្ធិ ជាមេធាវីការពារ និង ជាតំណាង ។

តតិយជនឈ្មោះ**ថែន ម៉ាន** អាយុ៥៥ឆ្នាំ ទីលំនៅផ្ទះលេខ១៤ ផ្លូវ៥៧ សង្កាត់បឹងកេងកង ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

**<u>កម្មវត្ថុបណ្ដឹង</u>** : ប្ដឹងទាមទារបែងចែកភាគហ៊ុន ។

បានឃើញបណ្ដឹងសាទុក្ខលើកទី២លេខ ២២៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០ របស់អ្នកស្រីខូវ ប៉ោសៀង ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣៥ "ឃ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចមិនសំរេចរឹបអូសអចលនវត្ថុរបស់ឈ្មោះខុងឆាលី ដែលបានមកដាក់បញ្ចាំនាងខ្ញុំដោយផ្ទាល់តាមកិច្ចសន្យា ចុះថ្ងៃទី០១ ខែមករា ឆ្នាំ ១៩៩៥ សូមឱ្យឈ្មោះ ខុង ឆាលី គោរពតាមកិច្ចសន្យា ។

បានឃើញបណ្ដឹងសាទុក្ខលើកទី២លេខ ៣០៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ របស់លោក ធៀន គង់ជិញ ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣៥"ឃ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញបណ្ដឹងសាទុក្ខលើកទី២លេខ ២៦០ ចុះថ្ងៃទី១៣ ខែ មិថុនា ឆ្នាំ២០០០ របស់លោកសៅ វីតា ជាមេធាវីរបស់ឈ្មោះ ខុង ឆាលី ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣៥ "ឃ" ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៥១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៥-០២-១៩៩៥ របស់ឈ្មោះ ធៀន គង់ជិញ ប្ដឹងសុំបែងចែកភាគហ៊ុនរបស់ខ្លួនក្នុងក្រុមហ៊ុនអាស៊ីថ្មីពាណិជ្ជ ពីឈ្មោះ ខុង ឆាលី ដោយសំអាងហេតុថា ក្នុងការ

បង្កើតក្រុមហ៊ុនអាស៊ីថ្មីនេះឈ្មោះខុង ឆាលី មានទុន៨០% ចំណែកខ្លួនមានទុន២០% ប្រាក់ប្រកាសដំបូងនៅក្រសួងពាណិជ្ជកម្មមានចំនួន ៨០.០០០$US ។ ក្នុងនោះឈ្មោះ ខុង ឆាលី មានចំនួន ៦៤.០០០$US ហើយខ្លួនមានចំនួន១៦.០០០$US ហើយក្នុងការរកស៊ីកន្លងមកជាបន្តបន្ទាប់ខ្លួនបានចេញប្រាក់ដើមទុនផ្ទាល់ខ្លួនចំនួន២០% ជាដរាប ។ ក្នុងការរកស៊ី ក្រុមហ៊ុនខ្លួនបានបំបែកចេញជាច្រើនសាខា ,សាខាជិញ លីញ នៅស្ទឹងមានជ័យខែ១០ឆ្នាំ១៩៩៣ មានប្រាក់ចំនួន២០០.០០០$US បានចុះកុងត្រារកស៊ីជាមួយក្រុមហ៊ុននៅប្រទេសចិន ។ ក្រុមហ៊ុនហ្វូកាងនៃខេត្តក្វាងទុងប្រទេសចិនបានចុះកុងត្រាជាមួយសាខាឈ្មោះ ជិញ ហ្វូ ក្នុងខែ៨-១៩៩៣ មានទឹកប្រាក់ចំនួន២០០.០០០$US ហើយក្រុមហ៊ុន ហ្វូ កាង នៃខេត្តក្វាងទុងនេះ ក៏បានចុះកុងត្រាជាមួយក្រុមហ៊ុនខ្លួន ក្នុងការផ្គត់ផ្គង់បរិក្ខាពេទ្យក្នុងខែសីហា ឆ្នាំ១៩៩៣ ដែលមានទឹកប្រាក់ ១០០.០០០$US ក្រុមហ៊ុនខ្លួនមានរថយន្តម៉ែសឺដែស៣០០ ចំនួន០១គ្រឿង តម្លៃ២៥.០០០$US រថយន្តតូយ៉ូតាកូរ៉ូឡា០១គ្រឿងតម្លៃ៨.០០០$ រថយន្តដឹកទំនិញម៉ាកនីសាន់ ០១គ្រឿងតម្លៃ៨.០០០$US រថយន្តទេសចរណ៍១២ប៉ាំង០១គ្រឿងតម្លៃ ១២៥០០$US ការសាងសង់ក្រុមហ៊ុនអស់ទឹកប្រាក់សរុបប្រហែល ២០០.០០០$US ទាំងអស់នេះខ្លួនមានដើមទុន២០% នៃប្រាក់ទាំងអស់ ។

ដោយឡែកខ្លួនចេញលុយផ្ទាល់មានភូមិគ្រឹះក្រុមហ៊ុនលេខ៣៣,៣៥ តម្លៃ២២០.០០០$US ទិញក្នុងខែ៤-១៩៩៣ ខ្លួនចេញ ៩៥.០០០$US ដីទំនេរក្បែរក្រុមហ៊ុនតម្លៃ៣៧.០០០$US ទិញក្នុងខែ៥ ឆ្នាំ១៩៩៣ ខ្លួនចេញទាំងអស់ ភូមិគ្រឹះនៅទួលគោកតម្លៃ ១១០.០០០$US ទិញក្នុងខែ៤ ឆ្នាំ១៩៩៣ ខ្លួនចេញទាំងអស់ ដីទំនេរនៅខេត្តកំពង់ស្ពឺមួយកន្លែងតម្លៃ ៤០.០០០$ ទិញក្នុងខែ៤ ឆ្នាំ១៩៩៣ រហូតដល់ខែ៦ ឆ្នាំ១៩៩៣ ខ្លួនចេញទាំងអស់ និង ដីទំនេរក្បែរអង់តែនវិទ្យុស្ទឹងមានជ័យតម្លៃ ៣៧.០០០$US ខ្លួនចេញអស់ប្រាក់ ៣៥.០០០$ ដូច្នេះខ្លួនចេញលុយបន្ថែមលើភាគហ៊ុន ២០% ទៀត សរុប ៣១៧.០០០$ ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី២៩-៣-១៩៩៦ របស់ឈ្មោះ លីង ស៊ិញហ្វូ ជាតតីយជនខាងដើមចោទ បានប្ដឹងទាមទារចែកភាគហ៊ុនចំនួន ១០% ពីប្រធានក្រុមហ៊ុនអាស៊ីពាណិជ្ជនាំចូលនាំចេញ ដោយសំអាងហេតុថា : ខ្លួនជាសមាជិកភាគហ៊ុននេះ ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ០១-១០-១៩៩៨ របស់ឈ្មោះ ខូវ ប៉ោសៀង ប្ដឹងសុំចូលជាតតីយជនក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២៥៤ ចុះថ្ងៃទី ០៩-០៧-១៩៩៨ របស់សាលាឧទ្ធរណ៍ ដោយសំអាងហេតុថា ឈ្មោះខុង ឆាលី បានយកវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១០៨៥២ ឱ្យខ្លួនកាលពីថ្ងៃទី០១-០១-១៩៩៥ ដោយខ្ចីប្រាក់ពីខ្លួនចំនួន ៦០.០០០$ ក្នុងរយៈពេលមួយឆ្នាំ បើលើសពីនេះសុខចិត្តចេញបង់ខាត ៥០% នៃប្រាក់ដែលខ្ចី ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១១៤"គ" ចុះថ្ងៃទី១៨ ខែ តុលា ឆ្នាំ១៩៩៦ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៩-០២-១៩៩៩ របស់ឈ្មោះធៀន គង់ជីញ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៩-៣-១៩៩៦របស់ឈ្មោះលីង ស៊ិញហ្វូ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣-រំលាយវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១០៨៥២ ចុះថ្ងៃទី២៥-៦-១៩៩២ លេខ ១៤៣៤១ ចុះថ្ងៃទី០៧-៤-១៩៩៣ និង លេខ ១៣១២៦ ចុះថ្ងៃទី១០-១២-១៩៩២ ចោលជាអសារបង់ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤-រឹបអូសផ្ទះលេខ៩ ផ្លូវ៩៥៤ សង្កាត់បឹងកក់ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញនិងដីទំនេរនៅភូមិចំការរដ្ឋ ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានព្រំប្រទល់ខាងកើតជាប់ទីបញ្ជាការយោធាស្រុក ខាងជើងជាប់ភូមិចំការរដ្ឋ ខាងត្បូងជាប់ផ្លូវជាតិលេខ៤ ខាងលិចជាប់ភូមិវល្លិ៍ស មានទំហំ៣០ហិកតា លក់ឡាយឡុង ហើយប្រគល់ប្រាក់ទៅឱ្យឈ្មោះធៀន គង់ជីញ ។

៥-រឹបអូសផ្ទះលេខ ៣៣ ,៣៥ ( លេខចាស់៩៧ )នៅសង្កាត់មិត្តភាព ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ លក់ឡាយឡុង ហើយប្រគល់ប្រាក់ឱ្យឈ្មោះធៀន គង់ជីញ ៥០,២១ភាគរយឱ្យឈ្មោះខុង ឆាលី ៤៩, ៨៧ភាគរយ ។

៦-រឹបអូសដីទល់មុខប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យ លក់ឡាយឡុង ហើយប្រគល់ប្រាក់ឱ្យឈ្មោះធៀន គង់ជីញ ៩៣,៣៣ ភាគរយ និងឱ្យឈ្មោះ ខុង ឆាលី ៦,៦៦ភាគរយ ។

៧-ប្រគល់ដី និង ផ្ទះលេខ ៧៤ នៅភូមិដំណាក់ធំ ផ្លូវរោងចក្រកែវ សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ អោយទៅឈ្មោះលីង សិញហ្វូ គ្រប់គ្រងចាប់តាំងពីថ្ងៃសាលក្រមចូលជាស្ថាពរ តែឱ្យឈ្មោះលីង ស៊ិញហ្វូ សងប្រាក់ចំនួន ១១៨.៦៩៣,៥៥ដុល្លាអាមេរិកទៅឱ្យឈ្មោះធៀន គង់ជីញ និង ខុង ឆាលី ។ ប្រាក់នេះត្រូវបែងចែក ៥០ភាគរយម្នាក់ ។

៨-អោយឈ្មោះលីង ស៊ិញហ្វូ សងប្រាក់ចំនួន ១៧.០០០$US ទៅអោយឈ្មោះធៀន គង់ជីញ និង ខុង ឆាលី វិញដោយឱ្យធៀន គង់ជីញ ៩.០០០$ និង ខុង ឆាលី៨.០០០$

៩-ទ្រព្យសម្បត្តិដែលនៅសល់ពីនេះ ហើយមានចែងក្នុងដីកាសំរេចកិច្ចការប្រញាប់លេខ០៩ប្រក ចុះថ្ងៃទី៣០-៣-១៩៩៥ ត្រូវចែកឱ្យឈ្មោះធៀន គង់ជីញ ២០ភាគរយ និងឈ្មោះខុង ឆាលី៨០% ។

១០-បង្គាប់ឱ្យឈ្មោះ ខុង ឆាលី សងប្រាក់ជំងឺចិត្តចំនួន ៥០.០០០$US ទៅឱ្យឈ្មោះធៀន គង់ជីញ ។ សំណូមពរលើសពីនេះ ត្រូវបដិសេធចោល ។

១១-បង្គាប់ឱ្យឈ្មោះធៀន គង់ជីញ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៣.០០០៛ រង្វាន់សាក្សី ២.០០០៛ បូករួម ៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុកជា

ស្រេច ។

កាលបើហួសបណ្តឹងឧទ្ធរណ៍ហើយ បង្គាប់អោយឈ្មោះ ធៀន គង់ជីញ , ខុង ឆាលី, លីង ស៊ិញហួ បង់ប្រាក់ពន្ធសមាមាត្រមួយភាគរយលើតម្លៃទ្រព្យសម្បត្តិដែលម្នាក់ៗ បានទទួលចំណែករៀងៗខ្លួន និង អោយឈ្មោះ ខុង ឆាលី បង់ពន្ធសមាមាត្រមួយភាគរយលើប្រាក់ជំងឺចិត្ត ៥០.០០០ស្ហបs (ហាសិបពាន់ដុល្លាអាមេរិក) ។ ប្រាក់នេះ ត្រូវបង់ចូលថវិការដ្ឋ៨០% និង សំរាប់ក្រឡាបញ្ជីទូទាំងប្រទេស ២០% តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

១២-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខធៀន គង់ជីញ,លីងស៊ិញហួ និងកំបាំងមុខ ខុង ឆាលី សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល២ខែ គិតចាប់ពីថ្ងៃផុតបណ្តឹងទាស់ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៦ របស់ឈ្មោះខុង ឆាលី ប្តឹងទាស់នឹងសេចក្តីសំរេចទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៦"គ" ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះខុង ឆាលី ចុះថ្ងៃទី២៨-១០-១៩៩៦ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១១៤"គ" ចុះថ្ងៃទី១៨-១០-១៩៩៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍រយៈពេល ២ខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះ សៅ វីតា ជាមេធាវីឱ្យឈ្មោះខុង ឆាលី មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៦"គ" ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៥៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៩-៤-១៩៩៨ របស់ឈ្មោះ សៅ វីតា មេធាវីឱ្យឈ្មោះខុង ឆាលី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងរបស់តតិយជនឈ្មោះ ខូវ ប៉ោសៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

៣-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១៦"គ" ចុះថ្ងៃទី១៨-០២-១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៤-សំរេចកាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វ៊ីង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង អាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០រៀល ។

៥-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខឈ្មោះធៀន-គង់ជីញ មេធាវី ឈ្មោះខៀវ សិទ្ធផន តំណាងឱ្យលោកខុង ឆាលី គឺលោកសៅ វីតា កំបាំងមុខតតិយជន ឈ្មោះលីង ស៊ិញហួ និងឈ្មោះខូវ ប៉ោសៀង បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ៦២"គ" ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ឈ្មោះខូវ ប៉ោសៀង ប្ដឹងទាស់ត្រង់ចំណុចសេចក្ដីទី២ នៃសាលដីកា ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៤ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍បានសំរេចសេចក្ដីចំពោះមុខឈ្មោះធៀន គង់ជីញ មេធាវីឈ្មោះ ខៀវ សិទ្ធផន កំបាំងមុខឈ្មោះខូវ ប៉ោសៀង ដែលមានខ្លឹមសារដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់លេខ ៦២ ចុះថ្ងៃទី ២៧-១១-១៩៩៨ របស់ឈ្មោះខូវ ប៉ោសៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្ដែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៦៥៦ ចុះថ្ងៃទី ១៥-១០-១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខឈ្មោះធៀន-គង់ជិញ មេធាវីឈ្មោះខៀវសិទ្ធផន កំបាំងមុខឈ្មោះខូវ ប៉ោសៀង បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៤០៥ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់លោកមេធាវីសៅ វីតា ជាមេធាវីតំណាងឱ្យលោក ខុង ឆាលី និងបណ្ដឹងសាទុក្ខលេខ ១១ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះ ខូវ ប៉ោសៀង ប្ដឹងមិនសុខចិត្តត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៨៣ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងសាទុក្ខលេខ៤០៥ចុះថ្ងៃទី២៤-១១-១៩៩៨របស់លោកសៅ វីតា មេធាវីលោក ខុង ឆាលី និងបណ្ដឹងសាទុក្ខលេខ ១១ ចុះថ្ងៃទី០៨-០១-១៩៩៩ របស់អ្នកស្រីខូវ-ប៉ោសៀង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៦៥៦ចុះថ្ងៃទី១៥-១០-១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ០៣ ចុះថ្ងៃទី ១៤-០១-១៩៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៣៨.០០០៛ ដែលលោកលីង ស៊ិញហ្វូ បានបង់ជូនរួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ្រីងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប១៩.០០០៛ នៅសល់ ១៩.០០០៛ បង្វិលឱ្យលោក លីង ស៊ិញហ្វូ វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៥-១០-១៩៩៩។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៥"ឃ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ៧០ចុះថ្ងៃទី២៧-១២-១៩៩៩ របស់សាលាឧទ្ធរណ៍ ដោយសាលដីកាលេខ ១៨៣ ចុះថ្ងៃទី០៥-១០-១៩៩៩ របស់តុលាការកំពូល ។

២-ទទួលពាក្យបណ្តឹងរបស់ដើមចោទធៀន គង់ជីញ ចុះថ្ងៃទី០៥-០២-១៩៩៥ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣-ទទួលពាក្យបណ្តឹងរបស់តតិយជនឈ្មោះ លីង ស៊ិញហ្វូ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៤-ទទួលពាក្យបណ្តឹងរបស់តតិយជន ខូវ ប៉ោសៀង សុំចូលជាតតិយជន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ និងសំរេចបញ្ចូលឈ្មោះនេះ ជាតតិយជន នៃរឿងក្តីនេះតទៅ ។

៥-រំលាយលក្ខន្តិកៈក្រុមហ៊ុន អាស៊ីថ្មី ពាណិជ្ជ នាំចេញ-នាំចូល ចុះថ្ងៃទី២៦-០៤-១៩៩៣ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៧-០៤-១៩៩៣ ចាប់ពីពេលនេះតទៅ ។

៦-បង្គាប់ឱ្យ ខុង ឆាលី និង ធៀន គង់ជីញ ប្រគល់ដី និងផ្ទះលេខ៧៤ នៅភូមិដំណាក់ធំ ផ្លូវរោងចក្រកែវ សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ទៅឱ្យតតិយជន លីង ស៊ិញហ្វូ គ្រប់គ្រងចាប់ពីពេលនេះតទៅ ប៉ុន្តែបង្គាប់ឱ្យលីង ស៊ិញហ្វូ សងប្រាក់ថ្លៃអាគារចំនួន ១១៨.៦៩៣,៥៥ដុល្លាអាមេរិក (ដប់មួយម៉ឺន ប្រាំបីពាន់ប្រាំមួយរយកៅសិបបី និងហាសិបប្រាំសេន) និងបំណុលចំនួន ១៧.០០០ដុល្លាអាមេរិក(មួយម៉ឺនប្រាំពីរពាន់) ទៅឱ្យ ខុង ឆាលី និង ធៀន គង់ជីញ វិញ ។

៧-ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនរួមមាន :

- ផ្ទះលេខ ៩ ផ្លូវ ៥៥៤ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

- ដីទំនេរនៅភូមិចំការរដ្ឋ ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានព្រំប្រទល់ខាងកើតជាប់ទីបញ្ជាការយោធាស្រុក ខាងជើងជាប់ភូមិចំការរដ្ឋ ខាងត្បូងជាប់ផ្លូវជាតិលេខ៤ ខាងលិចជាប់ផ្លូវវល្លិ៍ស មានទំហំ៣ហិកតា ។

- ផ្ទះលេខ ៣៣,៣៥ (លេខចាស់៩៧)នៅសង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

- ដីទល់មុខប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យ វៀរលែងតែដី និង ផ្ទះ ដែលបានសំរេចក្នុងចំណុចទី៦ នៃសាលដីកានេះ ។

- និងទ្រព្យសម្បត្តិផ្សេងពីទ្រព្យខាងលើ ដូចមានចែងក្នុងចំណុចទី២ នៃដីកាសំរេចកិច្ចការប្រញាប់លេខ០៩ប្រក ចុះថ្ងៃទី៣០-៣-១៩៩៥ របស់តុលាការក្រុងភ្នំពេញ រួមទាំងបំណុល ដូចមានចែងក្នុងចំណុចទី៦ នៃសាលដីកានេះ ត្រូវធ្វើការបែងចែកឬលក់ឡាយឡុងប្រគល់ទៅឱ្យឈ្មោះខុង ឆាលី ៣៩,៥៥% និងប្រគល់ទៅឱ្យឈ្មោះធៀន គង់ជីញ ៦០,៤៥% សំណូមពរលើសពីនេះបដិសេធចោល ។

៨-បង្គាប់ឱ្យរឹបអូសភាគហ៊ុនជាចំណែករបស់ខុងឆាលី ដើម្បីអនុវត្តសាលក្រមស្ថាពរលេខ ៦៥"គ" ចុះថ្ងៃទី០៩-១០-១៩៩៨ របស់តុលាការក្រុងភ្នំពេញ ឱ្យទៅឈ្មោះខូវ ប៉ោសៀង។

៩-កាត់យកប្រាក់ប្រដាប់ក្តីចំនួន ១៣.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

- បង្គាប់អោយឈ្មោះលីង ស៊ិញហួ បង់ពន្ធសមាមាត្រ១ភាគរយ លើប្រាក់ចំនួន ១៣៥.៦៩៣,៥៥ ដុល្លាអាមេរិក ឈ្មោះ ខុង ឆាលី បង់ពន្ធសមាមាត្រមួយភាគរយ លើភាគហ៊ុន ៣៩,៥៥% និងឈ្មោះធៀន គង់ជីញ បង់ពន្ធសមាមាត្រមួយភាគរយលើភាគហ៊ុន៦០,៤៥%។ ប្រាក់ពន្ធនេះ ៨០% សំរាប់ថវិការដ្ឋ និង ២០% សំរាប់រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

១០-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៨-៥-២០០០ និងប្រកាសជាសាធារណៈចំពោះមុខគ្រប់ភាគីនៅថ្ងៃទី២៣-៥-២០០០ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ ២៦០ ចុះថ្ងៃទី ១៣-០៦-២០០០ របស់លោក សៅ វីតា ជាមេធាវីការពារឱ្យលោក ខុង ឆាលី បណ្តឹងសាទុក្ខលើកទី២ លេខ២២៦ ចុះថ្ងៃទី ២៤-៥-២០០០ របស់ឈ្មោះខូវ ប៉ោសៀង និងបណ្តឹងសាទុក្ខលើកទី២លេខ ៣០៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ របស់លោក ធៀន គង់ជីញ ។

បានឃើញសាលដីការបៀបលេខ ១៨២ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបឱ្យធ្វើការសួរបញ្ជាក់ និងជូនឯកសារជាច្បាប់ដើមបន្ថែមពីគូភាគី។

ក្នុងករណីចាំបាច់ត្រូវធ្វើការស៊ើបអង្កេតរកភស្តុតាងបន្ថែម ។

២-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ។

បានស្តាប់របាយការណ៍បន្ថែមរបស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :រឿងនេះជារឿងវិវាទប្តឹងទាមទារបែងចែកភាគហ៊ុន និង ប្តឹងទាមទារប្រាក់ជំពាក់ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់អំណានលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២០-៩-២០០២ របស់ឈ្មោះខុង ឆាលី ។

បានស្តាប់អំណានលិខិតសុំដកពាក្យបណ្តឹងរបស់លោកខុង ឆាលីចុះថ្ងៃទី២៣-៩-២០០២។

បានស្តាប់អំណានសារណាបន្ថែមរបស់ឈ្មោះធៀន គង់ជីញ នៅពេលជំនុំជំរះ ។

បានស្តាប់អំណានសារណារបស់ឈ្មោះ ខូវ ប៉ោសៀង នៅពេលជំនុំជំរះ ។

បានស្តាប់ចំលើយរបស់ឈ្មោះលីង ស៊ីញហ្វ ជាគតិយជនដើមចោទនៅពេលសវនាការថា: ខ្លួនបានចូលហ៊ុន១០% ខ្លួនបានទិញដីពីរកន្លែង ដីខ្លួនទំហំទទឹង ២៦ម បណ្តោយ៥០ម ខ្លួនទុកឱ្យមេធាវីរបស់ខ្លួនឆ្លើយចុះ ។

បានស្តាប់ចំលើយរបស់ឈ្មោះប៉ែន អ៊ាន ជាគតិយជនចុងចម្លើយ នៅពេលសវនាការថា : ខុង ឆាលី បានជំពាក់ប្រាក់ខ្លួន ៣៨.០០០ ដុល្លាអាមេរិកពិតប្រាកដមែន តាមពិតមានពេលខ្លះខ្លួនបានផ្តល់ប្រាក់តាមរយៈមេធាវីចំនួន ១៥០០ដុល្លាអាមេរិក លោកមេធាវី សៅ វីតា យកមកដោះស្រាយក្នុងការងារ ។ ហើយខ្លួនបានចេញសោហ៊ុយឱ្យអ្នកថែរក្សាការពារទ្រព្យសម្បត្តិរៀងរហូតមក ។ សូមទាមទារជំងឺចិត្ត, ការប្រាក់, ប្រាក់ដើម ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ចុះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី សៅ វីតា ជាមេធាវីតំណាងឱ្យចុងចម្លើយ ជាម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា : ខ្លួនជាតំណាងឱ្យលោកខុង ឆាលី រហូតមក ដោយយោងតាមលិខិតពឹងពាក់ពីមុនមក បើលោកខុង ឆាលីដកពាក្យពីតុលាការកំពូលហើយ ខ្លួនយល់ថា បើកូនក្តីខ្លួនសំរេចដកហើយ ខ្លួនមិនចាំបាច់ការពារទៀតទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ខៀវ សិទ្ធផន ជាមេធាវីតំណាងអោយដើមចោទនាពេលសវនាការថា : ក្នុងរឿងនេះ ខ្លួនជាតំណាងរបស់ធៀន គង់ជីញ មុននឹងខ្លួនមានយោបល់ខ្លួនសូមឯកភាពសារណាបន្ថែមទាំងស្រុងរបស់លោកធៀន គង់ជីញ ។ ការបែងចែកភាគហ៊ុនមានសមាជិកលោកខុង ឆាលីមានភាគហ៊ុន៣៨% ចំណែកលោកលីង ស៊ីញហ្វ មានភាគហ៊ុនចំនួន១០% បានដាក់ចូលជាភាគហ៊ុនរួចហើយ ដែលមានលោក ខុង ឆាលី ជាម្ចាស់កម្មសិទ្ធិ ហើយលោក ខុង ឆាលី បានបន្ថែមប្រាក់ជាមួយលោក ធៀន គង់ជីញ ។ គ្មានសាលក្រមណាមួយ ត្រូវលប់អចលនវត្ថុស្ទឹងមានជ័យបានទេ ។ ចំណែកលោក ប៉ែន អ៊ាន លោកខុង ឆាលី បានទទួលស្គាល់រួចហើយ គាត់ជំពាក់ចំនួន ៣៨.០០០ ដុល្លាអាមេរិក អ្នកស្រី ខូវ ប៉ោសៀង ,

លោក ខុង ឆាលី មិនទទួលប្រាក់ជំពាក់ទេ ខ្លួនជាអ្នកតំណាងឱ្យលោក ធៀន គង់ជីញ មិនអាចសំរេចបានទេ ព្រោះរឿងនេះ ជារឿងរបស់អ្នកស្រីខូវ ប៉ោសៀង និងលោកខុង ឆាលី ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកលឹម វណ្ណា ជាមេធាវីការពារឱ្យលោកធៀន គង់ជីញ (ជាម្ចាស់បណ្តឹងសាទុក្ខ) បានលើកឡើងដូចតទៅ :ខ្លួនសូមរក្សាចំលើយរបស់មេធាវីខៀវ សិទ្ធផន តំណាងឱ្យលោកធៀន គង់ជីញ នៅដដែល ។ ខ្លួនជាមេធាវីការពារឱ្យលោកធៀន គង់ជីញ នៅតុលាការកំពូល រឿងពីមុនមក ខ្លួនមិនបានដឹងទេ ។ ខ្លួនជាមេធាវីការពារឱ្យលោកធៀន គង់ជីញ សូមបញ្ជាក់បន្ថែមទៅលើភាគហ៊ុនរបស់លោកខុង ឆាលី គាត់បានដកពាក្យបណ្តឹងហើយ បានផ្ទេរឱ្យកូនក្តីខ្លួនឈ្មោះធៀន គង់ជីញ ចំពោះបំណុលរបស់លោកប៉ែន អ៊ាន កូនក្តីខ្លួនព្រមទទួលសងសុំបន្ថែមលើការពាក់ព័ន្ធទៅនឹងលោក លីង ស៊ិញហ្វូ ១០% ដូច្នេះតុលាការថ្នាក់ក្រោម សំរេចមិនត្រឹមត្រូវតាមច្បាប់ទេ ។ ចំណែកអ្នកស្រី ខូវ ប៉ោសៀង តាមសារណារបស់កូនក្តីខ្លួន លោក ខុង ឆាលី មិនទទួលស្គាល់លិខិតខ្ចីបញ្ចាំចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៥ លោក ខុង ឆាលី បានដាក់ពាក្យជូនសម្តេច ជា ស៊ីម ប្រធានស្តីទី នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីបដិសេធលិខិតកិច្ចសន្យាខ្ចីប្រាក់ខាងលើ និងសើរើសាលក្រមលេខ៦៥"គ" ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ពាក្យបណ្តឹងនេះ លោកខុង ឆាលី ក៏បានដាក់ជូនតុលាការកំពូលដែរ ។ ដូច្នេះតតិយជនឈ្មោះខូវ ប៉ោសៀង មិនអាចទាមទារប្រាក់ ឬភាគហ៊ុនរបស់ខុង ឆាលី បានឡើយ ។ ចំណុចចុងក្រោយ ខ្លួនសូមសំណូមពរឱ្យតុលាការ មេត្តាសំរេចប្រគល់អចលនវត្ថុអាស៊ីថ្មីទាំងអស់មកឱ្យកូនក្តីខ្លួនមាន :

១-ផ្ទះលេខ ៣៣,៣៥ ផ្លូវ១២២ សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។

២-ផ្ទះលេខ ០៩ ផ្លូវ៥៩៤ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

៣-អាគារស្ទឹងមានជ័យលេខ ៧៤ ផ្លូវរោងចក្រកែវ សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

៤-ដីមួយកន្លែង នៅទល់មុខប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យ ។

៥-ដីទំនេរនៅភូមិចំការរដ្ឋ ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ ប្រគល់ទ្រព្យសម្បត្តិទាំងអស់ខាងលើនេះ ឱ្យកូនក្តីខ្លួនតាមសាលក្រមតុលាការក្រុងភ្នំពេញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ជីវ សាន ជាមេធាវីការពារ និង តំណាងឱ្យឈ្មោះ លីង ស៊ិញហ្វូ ជាតតិយជនដើមចោទ នៅពេលសវនាការថា : ខ្លួនសូមគោរព ឯកឧត្តមប្រធានតុលាការកំពូល ខ្លួនតំណាងឱ្យកូនក្តីខ្លួនឈ្មោះ លីង ស៊ិញហ្វូ មេត្តាជ្រាបថា : លីង ស៊ិញហ្វូ បានយកដី និងផ្ទះនៅស្ទឹងមានជ័យមកដាក់ក្នុងក្រុមហ៊ុនអាស៊ីថ្មី កូនក្តីខ្លួនត្រូវបានចំណែក១០% ក្នុងចំណែកក្រុមហ៊ុនទាំងមូល លើទ្រព្យសម្បត្តិរួមក្នុងក្រុមហ៊ុនទាំងមូល មិនមែនដូចមេធាវីរបស់លោកធៀន គង់ជីញ បានអះអាងនោះទេ ។លោកលីង ស៊ិញហ្វូ មានឯកសារគ្រប់គ្រាន់ដូចជា ឯកសារ

ទិញ លក់ ឯកសារកាន់កាប់ដី លិខិតឱ្យអនុញ្ញាតិឱ្យសាងសង់ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៣ ខ្លួនសូមបញ្ជាក់ថា ក្នុងអំឡុងវិវាទដោះស្រាយ មិនទាន់ចប់នៅឡើយទេ លោក ខុង ឆាលី និងលោក ផៀន គង់ជីញ រួមគំនិតគ្នាឱ្យផៀន គង់ជីញ កាន់កាប់ទ្រព្យសម្បត្តិទាំងអស់ ព្រោះមានសាលក្រមតុលាការក្រុងភ្នំពេញ ជាភស្តុតាងស្រាប់ ។ នៅក្នុងរឿងក្តីមិនទាន់ដោះស្រាយបែរមកដាក់ពាក្យបណ្តឹងថ្មី ដើម្បីមកបន្លំ ។កូនក្តីខ្លួនការពារនូវទ្រព្យសម្បត្តិរបស់គាត់ទាំងមូល ។ ខ្លួនសូមជំរាបជូនឯកឧត្តមប្រធានថា ពីដំបូងកូនក្តីខ្លួនបានទិញដីទំហំ២៦ម គុណ ៥០ម ពេលទិញដីមិនទាន់ស្គាល់ ផៀន គង់ជីញ និង ខុង ឆាលី ទេ ចំណែកភាគហ៊ុនលីង ស៊ិញហ្វូ ផ្ទះ និងដី នៅស្ទឹងមានជ័យ មានតំលៃស្មើនឹងក្រុមហ៊ុនទាំងមូល ដូច្នេះកូនក្តីខ្លួនទាមទារដី និងផ្ទះនៅស្ទឹងមានជ័យ ។ ខ្លួនសូមទាមទារសំណង់ និង អចលនទ្រព្យរបស់កូនក្តីខ្លួន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ហេង សុធាវណ្ណារិទ្ធិ ជាមេធាវីការពារ និងតំណាងឱ្យអ្នកស្រីខូវ ប៉ោសៀងជាតតិយជនចុងចម្លើយនៅពេលសវនាការថា :ខ្លួនសូមជំរាបជូនក្រុមប្រឹក្សាជំនុំជំរះតុលាការកំពូលមេត្តាជ្រាបថា : ឈ្មោះខុង ឆាលី បានមកខ្ចីប្រាក់ពីកូនក្តីខ្លួនចំនួន៦០.០០០ ដុល្លាអាមេរិក ដោយដាក់បញ្ចាំ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១០៨៥២ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩២ដែលជាផ្ទះលេខ៩ ផ្លូវ៥៥៤ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ អោយកូនក្តីខ្លួនដើម្បីធានាសំណង ។ ក្រោយពេលដែលកូនក្តីខ្លួនបានទំនាក់ទំនងសួរខាងជំនាញសុរិយោដី ឃើញថា វិញ្ញាបនប័ត្រនេះ ត្រឹមត្រូវហើយ និងជាកម្មសិទ្ធិរបស់លោក ខុង ឆាលី ពិតមែន កូនក្តីខ្លួនបានអនុញ្ញាតិឱ្យលោកខុង ឆាលី ខ្ចីប្រាក់ចំនួន ៦០.០០០ដុល្លាអាមេរិក ដោយបានធ្វើកិច្ចសន្យាខ្ចី, បញ្ចាំ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៥ ក្នុងរយៈពេល១ឆ្នាំ ។ លុះដល់ថ្ងៃកំណត់ ឈ្មោះនេះ បានមកអង្វរសុំពន្យាពេលនៃការសងប្រាក់ដើមមកកូនក្តីខ្លួនដោយយល់ឃើញថា ជាអ្នករកស៊ីដូចគ្នា ក៏សុខចិត្តអនុគ្រោះតាមការសុំរបស់ឈ្មោះ ខុង ឆាលី ទៅ ។ នៅឆ្នាំ១៩៩៨ ក៏បានប្តឹងផ្តល់គ្នាទៅតុលាការក្រុងភ្នំពេញ និងត្រូវបានតុលាការក្រុងភ្នំពេញចេញសាលក្រមលេខ ៦៥"គ" ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៨ សំរេចឱ្យខុង ឆាលី សងប្រាក់ចំនួន៦០.០០០ដុល្លាអាមេរិកទៅឱ្យកូនក្តីខ្លួន ។ សាលក្រមនេះ ត្រូវបានលោក ផៀន គង់ជីញ ប្តឹងផ្អាកការអនុវត្ត ដោយអាងហេតុថា ផ្ទះលេខ០៩ ផ្លូវ៥៥៤ សង្កាត់បឹងកក់ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញជារបស់ឈ្មោះ ខុង ឆាលី នេះ ជាទ្រព្យសម្បត្តិក្រុមហ៊ុនអាស៊ីថ្មី ។ ហើយកូនក្តីខ្លួន ក៏បានសុំចូលជាតតិយជន ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២៥៤ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ហើយក៏បន្តមកជាតតិយជនក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២៥១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ របស់តុលាការកំពូលនេះ ។តុលាការក្រុងភ្នំពេញ មិនបានស៊ើបអង្កេតឱ្យបានដិតដល់ទេ ដោយបានប្រគល់ទ្រព្យឱ្យលោក ផៀន គង់ជីញ ។ សាលក្រមលេខ ១២ "ប" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញជាកម្មវត្ថុពាក់ព័ន្ធដល់តុលាការកំពូលកំពុងដំណើរការនីតិវិធី ។ ខ្លួនជាតំណាង

ឱ្យតតិយជនឈ្មោះខូវ ប៉ោសៀង សំណូមពរ ៖

- ទទួលស្គាល់សាលក្រមលេខ ៦៥"គ" ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ និង យកអនុវត្តតាមច្បាប់ ។

- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១២"ប"ចុះថ្ងៃទី០៨ ខែមេសាឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ។

-បដិសេធលិខិតផ្ទេរសិទ្ធិទាំងឡាយរវាងឈ្មោះខុងឆាលីនិងឈ្មោះធៀន គង់ជីញ ដែលទទួលស្គាល់ដោយសាលក្រមលេខ១២"ប" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ។

- រឹបអូសផ្ទះលេខ៩ ផ្លូវលេខ៥៥៤ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញលក់ឡាយឡុង ដើម្បីទូទាត់សំណងទាំងអស់ឱ្យកូនក្តីខ្លួន និង ដាក់គុកបង្ខំរូបកាយ ករណីរឹងទទឹងពុំព្រមសង ។

- ទាមទារជំងឺចិត្តចំនួន ៥០០០០ដុល្លារអាមេរិក ។

. ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

. ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

. ក្រោយពីបានស្តាប់លិខិតផ្ទេរសិទ្ធិ និង ពាក្យសុំដកពាក្យបណ្តឹងរបស់លោក ខុង ឆាលី សារណារបស់អ្នកស្រីខូវ ប៉ោសៀង សារណាលោក ធៀន គង់ជីញ ចម្លើយលោកប៉ែន អ៊ាន និង លោក លឹង ស៊ុញហួ ព្រមទាំងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី និងមេធាវីតតិយជន .

. ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ២២៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០ របស់អ្នកស្រី ខូវ ប៉ោសៀង បណ្តឹងសាទុក្ខលេខ ៣០៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ របស់លោកធៀន គង់ជីញ និងបណ្តឹងសាទុក្ខលេខ២៦០ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០០ របស់លោកសៅ វីតា ជាមេធាវីលោកខុង ឆាលី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង តាមមាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផង ដែរ ។

- យល់ឃើញថា នៅតុលាការក្រុងភ្នំពេញ ដើមចោទបានប្តឹងទាមទារបែងចែកភាគហ៊ុនក្រុមហ៊ុនអាស៊ីថ្មី ពាណិជ្ជពីចុងចម្លើយ ប៉ុន្តែពេលដែលរឿងក្តីនេះ ចូលមកដល់តុលាការកំពូលតាមបណ្តឹងសាទុក្ខលើកទី២ របស់គូភាគី និង តតិយជន ចុងចម្លើយបានផ្ទេរសិទ្ធិទ្រព្យសម្បត្តិរបស់

ក្រុមហ៊ុនអោយដើមចោទ តាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២០-០៩-២០០២ ដែលមាន៣ទំព័រ ហើយដើមចោទក៏បានដាក់ពាក្យបណ្តឹង ចុះថ្ងៃទី០៣-១០-២០០២ សុំឱ្យតុលាការកំពូលអនុវត្តតាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២០-០៩-២០០២ របស់ចុងចម្លើយដែរ ។ ដូច្នេះ តុលាការកំពូលគប្បីលើកយកលិខិតផ្ទេរសិទ្ធិនេះ មកធ្វើជាមូលដ្ឋានក្នុងសំរេចសេចក្តីវិញ ។

- យល់ឃើញថា លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២០-០៩-២០០២ ដែលមាន៣ទំព័រ ត្រូវបានតុលាការកំពូលចាត់អោយធ្វើកោសល្យវិច្ច័យរួចហើយ ។ លទ្ធផលកោសល្យវិច្ច័យបញ្ជាក់ថា : ហត្ថលេខាលើលិខិតផ្ទេរសិទ្ធិនេះ ពិតជាហត្ថលេខាលោក ខុង ឆាលី ប្រាកដមែន ។

- យល់ឃើញថា ថ្វីបើដើមចោទ និង ចុងចម្លើយបានសុំដកពាក្យបណ្តឹង និង សុំអោយតុលាការកំពូលបញ្ចប់សំណុំរឿងរដ្ឋប្បវេណីរបស់ខ្លួនក៏ដោយ ក៏តុលាការកំពូលពុំអាចចំណាយរឿងនេះចេញដែរ ពីព្រោះរឿងក្តីនេះ នៅជាប់បណ្តឹងរបស់តតីយជនឈ្មោះ ខូវ ប៉ោសៀង ,ឈ្មោះ លីង ស៊ីញហ្វ ឈ្មោះប៉ែន អ៊ាន ។ ដូច្នេះតុលាការកំពូល គប្បីជំនុំជំរះរឿងនេះ តាមពាក្យបណ្តឹងរបស់តតីយជន ។

- យល់ឃើញថា ការដែលមេធាវីដើមចោទលើកឡើងនៅពេលសវនាការនេះ ក៏ដូចជាការលើកឡើងរបស់ដើមចោទក្នុងសារណាបន្ថែមចុះថ្ងៃទី២៧-៥-២០០៤ ដែរ ដែលថា សុំអោយតុលាការកំពូលសំរេចទទួលស្គាល់សាលក្រមស្ថាពរលេខ ១២"ប" ចុះថ្ងៃទី០៨-០៤-២០០៣ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះ ចៅក្រមតុលាការក្រុងភ្នំពេញ ដែលទទួលយកបណ្តឹងរបស់ដើមចោទមកជំនុំជំរះ គឺបានរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសមត្ថកិច្ចរបស់តុលាការកំពូល ដែលកំពុងតែចាត់ការរឿង ។ ម្យ៉ាងទៀតសាលក្រមនេះ សំរេចសេចក្តីពុំត្រឹមត្រូវគ្រប់គ្រាន់តាមខ្លឹមសារលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២០-០៩-២០០២ ទេ សំរេចបានតែពាក់កណ្តាលខ្លឹមសារប៉ុណ្ណោះ ត្រង់ការផ្ទេរសិទ្ធិពីចុងចម្លើយឱ្យដើមចោទ ឯកាតព្វកិច្ចរបស់ដើមចោទចំពោះចុងចម្លើយ និងតតិយជនពុំបានសំរេចទេ ហើយសាលក្រមនេះ ជំនុំជំរះកំបាំងមុខលោក ខុង ឆាលី និងតតីយជនទៀតផង ។

- យល់ឃើញថា ទ្រព្យសម្បត្តិផ្សេងៗទៀត ដែលមានចែងនៅក្នុងចំណុចទី២ នៃដីកាសំរេចកិច្ចការប្រញាប់លេខ ០៩ ប្រក.ចុះថ្ងៃទី៣០-៣-១៩៩៥ របស់តុលាការក្រុងភ្នំពេញ គូភាគីពុំបានលើកក្នុងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២០-០៩-២០០២ ទេ ។ ដូច្នេះ ចាត់ទុកថា គូភាគីបានដោះស្រាយរួចហើយ តុលាការកំពូលពុំគប្បីលើកយកមកសំរេចសេចក្តីទៀតទេ ។

- យល់ឃើញថា នៅក្នុងលិខិតផ្ទេរសិទ្ធិរបស់លោក ខុង ឆាលី ចុះថ្ងៃទី២០-៩-២០០២ និងនៅក្នុងសារណាបន្ថែម ចុះថ្ងៃទី២៧-៥-២០០៤ របស់លោក ធៀន គង់ជីញ បានទទួលស្គាល់បំណុល លោកប៉ែន អ៊ាន ចំនួន៣៨.០០០ដុល្លាអាមេរិក ហើយសុខចិត្តសងបំណុលនេះ ទាំងដើមទាំងការ ព្រមទាំងផ្តល់សោហ៊ុយខ្លះជូនលោកប៉ែន អ៊ាន ទុកជាការសងគុណ ។ លោកប៉ែន អ៊ានបានដាក់ពាក្យបណ្តឹងសុំចូលជាតតិយជននៅចំពោះមុខតុលាការ ហើយដោយសុំទាមទារប្រាក់ដើម

ការប្រាក់.ជម្ងឺចិត្ត និងថ្លៃថែរក្សាការពារទ្រព្យសម្បត្តិ ។ ដូច្នេះតុលាការកំពូល គប្បីសំរេចអំពីប្រាក់ដើម.ការប្រាក់៥% ក្នុង១ឆ្នាំ គិតពីថ្ងៃខ្ចី ថ្ងៃទី០២-០១-១៩៩៧ រហូតដល់ថ្ងៃសងគ្រប់ និង ប្រាក់ថ្លៃថែរក្សាការពារទ្រព្យសម្បត្តិចំនួន១០.០០០ដុល្លាអាមេរិក ឱ្យលោកប៉ែន អ៊ាន ។ ឯប្រាក់សាគុណលោក ប៉ែន អ៊ាន ពុំបានទាមទារទេ តុលាការកំពូលពុំគប្បីសំរេចឡើយ ។ ឯប្រាក់ជំងឺចិត្តដែលលោកប៉ែន អ៊ាន ទាមទារ ក៏តុលាការកំពូលពុំគប្បីពិចារណាដែរ ពីព្រោះលោកខុង ឆាលី ពុំមានប្រកែកតវ៉ាពីបំណុលនេះទេ ហើយនៅតែមានសុឆន្ទៈសងប្រាក់នេះ និង ដឹងគុណលោកជដែល ។

- យល់ឃើញថា ការដែលដើមចោទ និង ចុងចម្លើយបដិសេធមិនទទួលស្គាល់បំណុលរបស់តតិយជនឈ្មោះខូវ ប៉ោសៀង នោះជាការពុំត្រឹមត្រូវទេ ពីព្រោះបំណុលនេះ ត្រូវបានសំរេចជាស្ថាពរតាមសាលក្រមរដ្ឋប្បវេណីលេខ៦៥"គ"ចុះថ្ងៃទី០៩-១០-១៩៩៨ របស់តុលាការក្រុងភ្នំពេញហើយ ។ ម៉្យាងទៀត ពុំមានភស្តុតាងណាបញ្ជាក់ថា បំណុលនេះធ្វើឡើងដោយការគំរាមកំហែងទេ ហើយក៏ពុំមានច្បាប់បើកឱ្យប្តឹងសើរើ ក្នុងរឿងរដ្ឋប្បវេណីដែរ ។ ដូច្នេះ តុលាការកំពូល គប្បីទទួលបណ្តឹងតតិយជននេះ និង បង្គាប់ឱ្យអនុវត្តសាលក្រមរដ្ឋប្បវេណីស្ថាពរលេខ ៦៥"គ" ចុះថ្ងៃទី០៩-១០-១៩៩៨ ។

- យល់ឃើញថា ដើមចោទ និង ចុងចម្លើយ បានទទួលស្គាល់ភាគហ៊ុនរបស់តតិយជនឈ្មោះលីង ស៊ិញហួ ហើយប៉ុន្តែលោក ធៀន គង់ជីញ បានប្តឹងសាទុក្ខ និងតវ៉ាមិនប្រគល់ដី និងអាគារលេខ ៧៤ ផ្លូវរោងចក្រកែវ សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ អោយលោកលីង ស៊ិញហួ ដោយទទួលយកប្រាក់ថ្លៃសាងសង់អាគារចំនួន ១១៨.៦៩៣.៩៥ ដុល្លាអាមេរិក និងប្រាក់ជំពាក់ចំនួន ១៧.០០០ដុល្លាអាមេរិក ពីលោកលីង ស៊ិញហួ នោះទេ ។ ហើយលោកទាមទារឱ្យបែងចែកភាគហ៊ុន១០% លើតម្លៃដី និង អាគារលេខ ៧៤នេះ ។

ការទាមទារបែបនេះ ជាការពុំត្រឹមត្រូវទេ ពីព្រោះលោកធៀន គង់ជីញ ពុំបានប្តឹងឧទ្ធរណ៍ពីសាលក្រមរដ្ឋប្បវេណីលេខ ១១៤"គ" ចុះថ្ងៃទី១៨-១០-១៩៩៦ របស់តុលាការក្រុងភ្នំពេញ និងពុំបានប្តឹងសាទុក្ខលើកទី១ ពីសាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍លេខ ៦៥៦ ចុះថ្ងៃទី១៥-១០-១៩៩៨ និងលេខ ០៤ ចុះថ្ងៃទី០៤-០១-១៩៩៩ ទេ ។ ដូច្នេះការប្តឹងសាទុក្ខ និងសាលដីការដ្ឋប្បវេណីលេខ ៣៥"ឃ" ចុះថ្ងៃទី២៣-៥-២០០០ ដែលបានសំរេចអំពីដី និង អាគារលេខ៧៤នេះ ជាលើកទី២ ដែលដូចគ្នា និងការសំរេចលើកទី១ដែរនោះ តុលាការកំពូលពុំអាចពិចារណានិងធ្វើការកែប្រែបានឡើយ ។ ម៉្យាងទៀត ដីនេះជាដីលោកលីង ស៊ិញហួ ដូច្នេះការប្រគល់ដីឱ្យម្ចាស់គេវិញ ហើយតម្រូវឱ្យលោកលីង ស៊ិញហួ ចេញថ្លៃសំណង់ជូនដើមចោទ និង ចុងចម្លើយនោះ គឺជាការត្រឹមត្រូវហើយ ។ លើសពីនេះទៀត បណ្តឹងសាទុក្ខលោក ធៀន គង់ជីញ ធ្វើឡើងហួសកំណត់ច្បាប់ ។

- យល់ឃើញថា ការដែលលោក អ៊ុក ភូរិ ប្តឹងសុំចូលជាតតិយជន ទាមទារថ្លៃសេវា

មេធាវីពីលោកធៀន គង់ជីញ នោះ តុលាការកំពូល ពុំអាចពិចារណាបានទេ ពីព្រោះរឿងនេះ ជាអង្គហេតុថ្មី ហើយពុំមានពាក់ព័ន្ធជាមួយក្រុមហ៊ុនអាស៊ីថ្មីពាណិជ្ជ និង ពុំមានការយល់ព្រមពីគូភាគីដែរ ដូច្នេះរឿងនេះ ជាសមត្ថកិច្ចរបស់តុលាការក្រុងភ្នំពេញ ។

- យល់ឃើញថា លោកធៀន គង់ជីញ ,លោក ខុង ឆាលី និងអ្នកស្រីខូវ ប៉ោសៀង បានធ្វើសារណា និងពាក្យបណ្តឹងបន្ថែម ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះ តុលាការកំពូល ជំនុំជំរះ កំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣៥"ឃ" ចុះថ្ងៃទី២៣-៥-២០០០ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីកន្លងមក គឺសំរេចផ្អែកលើមូលដ្ឋាននៃការបែងចែកភាគហ៊ុន ប៉ុន្តែស្រាប់តែគូភាគី បានស្រុះស្រួលគ្នាផ្សេងពីការបែងចែកភាគហ៊ុន នៅពេលសាទុក្ខលើកទី២ហើយ តុលាការកំពូលជំនុំជំរះទាំងអង្គហេតុ និង អង្គច្បាប់ ដូច្នេះគប្បីទុកជាមោឃៈសាលដីកានេះទាំងមូល និង សំរេចសេចក្តីជាថ្មី ដើម្បីអោយបានត្រឹមត្រូវតាមការព្រមព្រៀងរបស់គូភាគី និង ការពារផលប្រយោជន៍របស់តតិយជនផង ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខលោក ប៉ែន អ៊ាន**

**លោក លឹង ស៊ិញហ្វួ ,កំបាំងមុខលោក ធៀន គង់ជីញ**

**លោក ខុង ឆាលី និងអ្នកស្រីខូវ ប៉ោសៀង ប៉ុន្តែ ចាត់ទុកជាចំពោះមុខ**

១-លើកបណ្តឹងសាទុក្ខលើកទី២លេខ ៣០៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ របស់លោកធៀន គង់ជីញ ចោលជាអសារបង់ ។

២-ទទួលបណ្តឹងសាទុក្ខលើកទី២លេខ ២២៦ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០ របស់អ្នកស្រីខូវ ប៉ោសៀង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣-លើកចោលនូវបណ្តឹងសាទុក្ខលើកទី២លេខ ២៦០ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០០ របស់លោកសៅ វីតា ជាមេធាវីលោក ខុង ឆាលី ចោលជាអសារបង់តាមសំណើរបស់សាម៉ីខ្លួន ។

៤-លើកបណ្តឹងសុំចូលជាតតិយជនរបស់លោកអ៊ុក ភូរិ ចោលជាអសារបង់ ។

៥-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៣៥"ឃ" ចុះថ្ងៃទី២៣-៥-២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៦-ទទួលពិចារណាពាក្យបណ្តឹង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០២ របស់លោក

ខុង ឆាលី និងពាក្យបណ្តឹងចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់លោកធៀនគង់ជីញ សុំអោយទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២ របស់លោកខុង ឆាលី ។

៧-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០២ របស់លោក ខុង ឆាលី ដែលមាន៣ទំព័រ ទុកជាត្រឹមត្រូវតាមច្បាប់ លើកលែងតែចំណុចទី៣ ទំព័រទី២ និងចំណុចទី២ ទំព័រទី៣ ដែលត្រូវទុកជាមោឃៈ ។

៨-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៨ ខែមិនា ឆ្នាំ១៩៨៦ របស់លោកលីង ស៊ិញហ្វូ ពាក្យបណ្តឹងចុះថ្ងៃទី០១-១០-១៩៩៨ របស់អ្នកស្រីខូវ ប៉ោសៀង និងពាក្យបណ្តឹងចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៣ របស់លោកប៉ែនអ៊ាន ដែលប្តឹងសុំចូលជាតតិយជនទុកជាត្រឹមត្រូវតាមច្បាប់។

៩-ប្រគល់ដី និងអាគារលេខ ៧៤ នៅភូមិដំណាក់ធំ ផ្លូវរោងចក្រកែវ សង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ ឱ្យលោក លីង ស៊ិញហ្វូ ជាតតិយជន កាន់កាប់គ្រប់គ្រងតទៅ ប៉ុន្តែលោកលីង ស៊ិញហ្វូ ត្រូវសងប្រាក់ថ្លៃអាគារចំនួន១១៨.៦៩៣.៥៥ ដុល្លាអាមេរិក និងប្រាក់បំណុលចំនួន១៧.០០០ដុល្លាអាមេរិក ឱ្យលោកធៀន គង់ជីញ បើលោកលីង ស៊ិញហ្វូ ពុំព្រមប្រគល់ប្រាក់ដូចចំនួនខាងលើទេ សំរេចរឹបអូសដី និង អាគារនេះលក់យកប្រាក់សង លោកធៀន គង់ជីញ ប្រាក់នៅសល់ប្រគល់ឱ្យលោក លីង ស៊ិញហ្វូ ។

១០-បង្គាប់អោយលោក ធៀន គង់ជីញ និងលោកខុង ឆាលី សងប្រាក់អ្នកស្រីខូវ ប៉ោសៀង តាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ ៦៥"គ" ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៨។ បើរឹងរូស ឬគ្មានប្រាក់សងត្រូវអនុវត្តតាមវិធានការណ៍ដែលចែងឱ្យដាក់គុកបង្ខំលើរូបកាយ ឬរឹបអូសអចលនទ្រព្យដាក់ធានាជាមួយអ្នកស្រី ខូវ ប៉ោសៀង លក់ឡាយឡុងសងសំណងនេះ ។

១១-បង្គាប់ឱ្យលោកធៀន គង់ជីញ សងលោក ប៉ែន អ៊ាន នូវប្រាក់ដើមចំនួន ៣៨.០០០ដុល្លាអាមេរិក, ការប្រាក់៥% ក្នុងមួយឆ្នាំ គិតពីខែ០១-១៩៩៧ ដល់ថ្ងៃសងគ្រប់ និងសងសោហ៊ុយថែរក្សាការពារទ្រព្យសម្បត្តិចំនួន១០.០០០ដុល្លាអាមេរិក ។ ក្នុងករណីគ្មានប្រាក់សងត្រូវរឹបអូសអចលនទ្រព្យដែលបានរៀបរាប់នៅក្នុងលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២០-៩-២០០២ លក់ឡាយឡុងសងម្ចាស់បំណុល ។ បើរឹងរូស ត្រូវដាក់គុកបង្ខំលើរូបកាយដើម្បីទារសំណង ។

១២-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៣៨.០០០រៀល ដែលលោក ខុង ឆាលី និងអ្នកស្រីខូវ ប៉ោសៀង បានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .
- ចំណាយលើការប្រគល់ដីកាកោះ ចំនួន ១៥.០០០៛ សរុប ១៩.០០០៛ នៅសល់ចំនួន ១៩.០០០៛ ប្រគល់ឱ្យអ្នកស្រីខូវ ប៉ោសៀង វិញ ។

បង្គាប់ឱ្យលោកធៀន គង់ជីញ បង់ពន្ធសមាមាត្រ១%លើប្រាក់ដែលត្រូវសងលោកប៉ែនអ៊ាន

អ្នកស្រីខូវ ប៉ោសៀង និងបង្គាប់ឱ្យលោកលឹង ស៊ិញហួ បង់ពន្ធសមាមាត្រ ១% លើប្រាក់ដែលត្រូវសងទៅលោកធៀន គង់ជីញ ។

១៣-សាលដីកានេះ ជំនុំជំរះ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៤ និង ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ ។